# អដ្ឋកថា សតធម្មជាតក

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការស្វែងរកមិនប្រពៃ ២១ ប្រការ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **តញ្ច អប្បញ្ច ឧច្ឆិដ្ឋំ** ដូច្នេះជាដើម ។

បានឮថា សម័យមួយ ភិក្ខុជាច្រើនសម្រេចការចិញ្ចឹមជីវិតដោយអនេសនៈ ២១ យ៉ាង គឺ ធ្វើជាពេទ្យ ធ្វើជាទូត ធ្វើជាអ្នកបញ្ជូនសារ ធ្វើជាអ្នកបម្រើ ឲ្យឈើស្ទន់ ឲ្យឫស្សី ឲ្យផ្កាឈើ ឲ្យផ្លែឈើ ឲ្យលម្អិតសម្រាប់លាប ឲ្យគរុកណ្ឌ ឲ្យថ្នាំ ឲ្យបិណ្ឌបាត ការស្វែងរកមិនគួរនោះ នឹងមានជាក់ច្បាស់ក្នុង **សាកេតជាតក** [១] ឯណោះ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបការចិញ្ចឹមជីវិតរបស់ភិក្ខុទាំងនោះហើយ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ ភិក្ខុជាច្រើនសម្រេចការចិញ្ចឹមជីវិតដោយការស្វែងរកមិនគួរ លុះសម្រេចការចិញ្ចឹមជីវិតបែបនេះហើយ មិនរួចអំពីភាពជាយក្ស ភាពជាប្រេត នឹងកើតជាគោទឹមរទេះ នឹងកើតក្នុងនរក តថាគតគួរពោលធម្មទេសនាណាមួយ ដែលជាអជ្ឈាស្រ័យរបស់ខ្លួន ដើម្បីឲ្យកើតបញ្ញា ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខនៃភិក្ខុទាំងឡាយ

---

១-ក្នុង **សាកេតជាតក** មិនឃើញពោលអំពីអនេសនៈ ២១ ប្រហែលជានៅក្នុងជាតកដទៃទេដឹង តែបាលីលោកពោលទុកយ៉ាងនេះ ទើបយើងរក្សាទុក ។

ទើបទ្រង់ត្រាស់ឲ្យហៅភិក្ខុទាំងនោះប្រជុំគ្នា ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមិនគួរញ៉ាំងបច្ច័យឲ្យកើតឡើងដោយការស្វែងរកមិនគួរ ២១ យ៉ាងឡើយ ព្រោះបិណ្ឌបាតដែលកើតឡើងដោយការស្វែងរកមិនគួរ ដូចដុំទង់ដែងក្តៅ ដូចថ្នាំពុលដ៏ពន្លឹក ពិតណាស់ ការស្វែងរកមិនគួរនេះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះពុទ្ធ តិះដៀល ជំទាស់ កាលភិក្ខុបរិភោគបិណ្ឌបាតដែលកើតឡើងដោយការស្វែងរកមិនគួរ នឹងមិនមានសេចក្តីរីករាយសោមនស្សឡើយ ព្រោះថាបិណ្ឌបាតដែលកើតឡើងយ៉ាងនេះ ដូចជាអាហារសល់របស់មនុស្សចណ្ឌាល ។ ក្នុងសាសនាតថាគត ការបរិភោគបិណ្ឌបាតនោះ រមែងដូចជាការបរិភោគអាហារសំណល់របស់មនុស្សចណ្ឌាល ឈ្មោះសតធម្មមាណពដូច្នោះ ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតមនុស្សចណ្ឌាល ចម្រើនវ័យដោយលំដាប់ ។ ថ្ងៃមួយ បានត្រៀមអង្ករជាស្បៀងនិងកញ្ចប់បាយធ្វើដំណើរទៅដោយករណីយកិច្ចឯណានីមួយ ។ ក្នុងកាលនោះ នៅក្នុងនគរពារាណសី មានមាណពម្នាក់ឈ្មោះ សតធម្ម កើតក្នុងត្រកូលព្រាហ្មណមហាសាល ឧទិច្ចគោត្ត ។ មាណពនោះ មិនបានត្រៀមស្បៀងសម្រាប់ដើរផ្លូវទេ ធ្វើដំណើរទៅដោយកិច្ចឯណានីមួយ ទាំងពីរ

នាក់បានមកជួបគ្នានៅត្រង់ផ្លូវធំ ។

មាណពនោះក៏សួរព្រះបរមពោធិសត្វថា អ្នកមានជាតិជាអ្វី ?

ព្រះបរមពោធិសត្វឆ្លើយថា ខ្ញុំជាមនុស្សចណ្ឌាល ហើយព្រះមហាសត្វសួរមាណពនោះថា អ្នកមានជាតិជាអ្វីដែរ ?

មាណពនោះឆ្លើយថា ខ្ញុំមានជាតិជាព្រាហ្មណ៍ឧទិច្ចគោត្ត ។

ព្រះមហាសត្វពោលថា ប្រពៃហើយ យើងទៅជាមួយគ្នា ទាំងពីរនាក់ក៏ធ្វើដំណើររួមគ្នា ។ លុះដល់ពេលអាហារព្រឹក ព្រះពោធិសត្វក៏អង្គុយក្នុងទីរកទឹកបានងាយ លាងដៃស្រាយកញ្ចប់បាយ ហើយពោលថា **មាណវ ភត្តំ ភុញ្ជាហិ** នៃមាណព ចូរបរិភោគចុះ ។

មាណពនោះពោលថា **នត្ថិ ហរេ ចណ្ឌាល មម ភត្តេន អត្ថោ** នៃអ្នកជាតិចម្រើន ការដែលយើងត្រូវការអាហាររបស់មនុស្សចណ្ឌាលនោះ មិនដែលមានឡើយ ។

ព្រះពោធិសត្វក៏ពោលថា តាមចិត្តរបស់អ្នកចុះ ហើយចាប់យកអាហារល្មមតែបរិភោគខ្លួនឯង ដាក់លើស្លឹកឈើដទៃ មិនធ្វើអាហារដែលនៅក្នុងកញ្ចប់ឲ្យជាអាហារសល់ដែល រួចខ្ចប់ទុកម្ខាង បរិភោគផឹកទឹករួចស្រេចហើយ ក៏លាងដៃ លាងជើង កាន់យកអង្ករនិងអាហារដែលសេសសល់ រួចពោលថា មកមាណព យើងទៅ ហើយក៏ធ្វើដំណើរទៅទៀត ។ ព្រះមហាសត្វនិងមាណពនោះ ធ្វើដំណើរទៅរហូតដល់ពេល

ស្រេចល្ងាច ទាំងពីរនាក់នាំគ្នាចុះងូតក្នុងទីដែលមានទឹកសម្បូណ៌មួយ ហើយហើយក៏ឡើងមកវិញ ។ ព្រះពោធិសត្វអង្គុយក្នុងទីសប្បាយមួយ ហើយក៏លាកញ្ចប់អាហារដោយមិនបានហៅមាណពនោះទេ ផ្តើមបរិភោគ ។ មាណពនោះ នឿយហត់ព្រោះការធ្វើដំណើរពេញមួយថ្ងៃ កើតការឃ្លានបាយបានត្រឹមតែឈរសម្លឹងមើលដោយគិតថា ប្រសិនបើមនុស្សចណ្ឌាលនេះឲ្យអាហារដល់អញ អញក៏នឹងបរិភោគ ។ ចំណែកព្រះពោធិសត្វ ក៏មិនបាននិយាយអ្វីទាំងអស់ គិតតែពីបរិភោគតែម្យ៉ាង មាណពនោះ គិតថា មនុស្សចណ្ឌាលនេះ មិននិយាយអ្វីនឹងអញសោះ គង់បរិភោគរហូតទាល់តែអស់ អញគួរដណ្តើមយកអាហារនេះទុក គៀរយកអាហារខាងលើចោល ហើយបរិភោគអាហារដ៏សេស មាណពនោះបានធ្វើដូច្នោះ ហើយបរិភោគអាហារសំណល់ ( អំពីមនុស្សចណ្ឌាល ) ។ លុះបរិភោគហើយភ្លាម ក៏កើតការក្តៅក្រហាយចិត្តយ៉ាងខ្លាំងថា អញបានធ្វើនូវអំពើមួយដែលមិនសមគួរដល់ជាតិ គោត្ត ត្រកូល និងប្រទេសរបស់ខ្លួន អញបានបរិភោគអាហារដែលជារបស់សល់អំពីមនុស្សចណ្ឌាល ។ ភ្លាមនោះឯង អាហារលាយឈាមក៏ក្អួតចេញអំពីមាត់មាណពនោះ ។ មាណពនោះខ្ញាយំ ព្រោះសេចក្តីសោកដ៏ខ្លាំងកើតឡើងថា អញបានធ្វើអំពើដែលមិនសមគួរ ព្រោះហេតុត្រឹមតែអាហារបន្តិចបន្តួច ហើយពោលគាថាទី ១ ថា

តញ្ច អប្បញ្ច ឧច្ឆិដ្ឋំ　　តញ្ច កិច្ឆេន នោ អទា
សោហំ ព្រាហ្មណជាតិកោ　　យំ ភុត្តំ តម្បិ ឧគ្គតំ ។

( អាហារណា ដែលបានបរិភោគហើយ ) បាយនោះជារបស់តិចផង សល់ដែលផង បុរសចណ្ឌាល បានឲ្យបាយនោះដល់យើង ដោយសេចក្ដីពិបាក យើងប្រកបដោយជាតិជាព្រាហ្មណ៍ អាហារណា ដែលយើងបានបរិភោគហើយ អាហារនោះឯង ក៏ក្អួតចេញមក ។

គាថានោះមានសេចក្ដីសង្ខេបដូចតទៅនេះ អញបរិភោគអាហារណា អាហារនោះតិចផង សល់ដែលផង បុរសចណ្ឌាលនោះ មិនបានឲ្យអាហារដល់អញដោយការពេញចិត្តរបស់ខ្លួនទេ ពិតណាស់ គ្រូអញដណ្ដើមយក ទើបឲ្យដោយសេចក្ដីលំបាក គឺដោយការលំបាក អញជាព្រាហ្មណ៍មានជាតិបរិសុទ្ធ ព្រោះហេតុនោះ អាហារដែលអញបរិភោគនោះ ទើបក្អួតចេញមកជាមួយនឹងឈាម ។

មាណពនោះទួញយំយ៉ាងនេះហើយ ទើបគិតថា អញបានធ្វើអំពើដែលមិនសមគួរ ដូច្នេះហើយ នឹងរស់នៅធ្វើអ្វីទៀត ទើបចូលកាន់ព្រៃ មិនបង្ហាញខ្លួនឲ្យអ្នកណាឃើញឡើយ ក្រោយមកធ្វើមរណកាលដោយយ៉ាងអនាថា ។

ព្រះបរមសាស្ដា ទ្រង់សម្ដែងរឿងក្នុងអតីតនេះហើយ ទើបត្រាស់

៣ ម្នាលភិក្ខុទាំងឡាយ ព្រោះសតធម្មមាណពបរិភោគអាហារសល់របស់បុរសចណ្ឌាលនោះ ជាការបរិភោគអាហារដែលមិនសមគួរដល់ខ្លួន ទើបមិនបាននូវសេចក្ដីរីករាយយ៉ាងណា បុគ្គលណាបួសហើយក្នុងសាសនានេះក៏យ៉ាងនោះដែរ សម្រេចការចិញ្ចឹមជីវិតដោយការស្វែងរកដែលមិនសមគួរ បរិភោគបច្ច័យដែលបានមកដោយមិនសមគួរ សេចក្ដីត្រេកអរមិនកើតឡើងដល់ភិក្ខុនោះ ព្រោះភិក្ខុនោះមានជីវិតរស់នៅដែលគួរឲ្យតិះដៀល ដែលព្រះពុទ្ធអង្គទ្រង់ហាមឃាត់ ។ លុះទ្រង់សម្រេចអភិសម្ពោធិញ្ញាណហើយ ទើបត្រាស់ព្រះគាថាទី ២ ៣

ឯវំ ធម្មំ និរង្កត្វា យោ អធម្មេន ជីវតិ
សតធម្មោ វ លាភេន លទ្ធេនាបិ ន នន្ទតិ ។

ភិក្ខុណាលះបង់នូវធម៌ គឺអាជីវបារិសុទ្ធិសីល ហើយចិញ្ចឹមជីវិតដោយខុសធម៌យ៉ាងនេះ ភិក្ខុនោះមិនត្រេកអរ ដោយលាភដែលខ្លួនបានហើយ ដូចជាសតធម្មមាណព ។

បណ្ដាបទទាំងនោះ បទថា ធម្មំ បានដល់ ធម៌ គឺ អាជីវបារិសុទ្ធិសីល ។

បទថា និរង្កត្វា បានដល់ យកទៅបោះចោល ។

បទថា អធម្មេន បានដល់ មិច្ឆាជីវៈ ពោលគឺអនេសនៈ ២១ ។

បទថា សតធម្មោ ជាឈ្មោះរបស់មាណពនោះ ។ បាលីជា

សុតធម្មោ ក៏មាន ។

បទថា ឧ ឧជ្ឈតិ សេចក្តីថា សតធម្មមាណពមិនត្រេកអរដោយលាភនោះថា អញបានអាហារដែលជាសំណល់របស់បុរសចណ្ឌាលយ៉ាងណា កុលបុត្តដែលបួសក្នុងសាសនានេះក៏ដូច្នោះដែរ បរិភោគលាភដែលបានមកដោយអនេសនៈ រមែងមិនត្រេកអរ មិនបានសុខហើយដល់នូវទោមនស្សថា អញរស់នៅដោយការចិញ្ចឹមជីវិតដែលព្រះពុទ្ធទ្រង់តិះដៀល ព្រោះហេតុនោះ បុគ្គលដែលចិញ្ចឹមជីវិតដោយអនេសនៈ គួរចូលព្រៃស្លាប់យ៉ាងអនាថាប្រសើរជាង ដូចជាសតធម្មមាណពដូច្នោះ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសអរិយសច្ចៈ កាលចប់អរិយសច្ចៈ ភិក្ខុជាច្រើនបានសម្រេចសោតាបត្តិផលជាដើម ហើយទ្រង់ប្រជុំជាតកថា សតធម្មមាណពក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ក្មេងចណ្ឌាលក្នុងកាលនោះ គឺ **តថាគត** នេះឯង ។

**ចប់ អដ្ឋកថា សតធម្មជាតក ទី ៩ ។**